# សូមស្វាគមន៍!

*យើងនឹងចាប់ផ្តើមក្នុងពេលបន្តិចទៀតនេះ។*

**អង្គប្រជុំការស្តាប់លើកទី #1**

ថ្ងៃទី8 ខែធ្នូ ឆ្នាំ2021 | 5:30 pm to 7:00 pm

Metro




# We're developing a new vision for the 710 corridor.

I-710 TASK FORCE

Metro

# Interpretation / *Interpretación /kar bakasray / Interpretasyon*

***ដើម្បីស្តាប់ការប្រជុំជាភាសាផ្សេង***

***Español***:

- *Llamada en español:* 872.240.3212
- *Código de acceso:* 290-700-629

***Khmer:***

- *សេចក្តីលម្អិតអំពីការហៅចូលប្រជុំ: 646.749.3335*
- *លេខកូដចូលប្រើ: 130-661-317*

***Tagalog:***

- *Mga Detalye sa Call-in sa Pagpupulong : 571.317.3122*
- *Kodigo: 195-017-525*

***Tech Support - Google phone line/text***

- Phone: 323.609.3345
- *monitoring, translation support*

Metro

# Raise Hand / *Levantar la mano*

*During the comment sessions:*

> Click **Raise Hand** in your meeting controls or
> **Press*9** on the phone line.
> To lower your hand, click **Raise Hand** in your meeting controls.
> Comments & questions can also be provided in writing by using the **Q&A** function.
> The **Q&A** button is located on the control panel at the bottom of your screen.
> If you're listening in on our Spanish, Khmer or Tagalog **phone** call-in lines and have a question or comment, please **press *6** to unmute yourself and let the interpreter know.

> *សូមចុចលើពាក្យ Raise Hand (លើកដៃ) នៅក្នុងការគ្រប់គ្រង ការប្រជុំ របស់អ្នក ឬ*
> *ចុច *9 នៅលើខ្សែទូរស័ព្ទ។*
> *ដើម្បីដាក់ដៃរបស់អ្នកចុះ សូមចុចពាក្យ Raise Hand (លើកដៃ) នៅក្នុងការគ្រប់គ្រងការប្រជុំ របស់អ្នក។*
> *យោបល់ & សំណួរ ក៏អាចផ្តល់ឲ្យជាលាយលក្ខណ៍អក្សរ ដោយប្រើមុខងារ Q&A (សំណួរ & ចម្លើយ)។*
> *ប៊ូតុង Q&A (សំណួរចម្លើយ) មានទីតាំងស្ថិតនៅលើផ្ទាំង បញ្ជា ផ្នែកខាងក្រោមនៃ អេក្រង់ របស់ អ្នក។*
> *ប្រសិនបើអ្នកស្តាប់ខ្សែទូរសព្ទហៅចូលជាភាសាអេស្ប៉ាញ ខ្មែរ ឬតាហ្គាឡុករបស់យើង ហើយមាន សំណួរ ឬមតិយោបល់ សូមចុច *6 ដើម្បីបើកសំឡេងខ្លួនឯង ហើយប្រាប់អ្នកបកប្រែឱ្យដឹង។*

Metro

# ការស្វាគមន៍ សេចក្តីណែនាំ និងរបៀបវារៈ

Metro

# អ្នកសម្របសម្រួល និងអ្នកធ្វើបទបង្ហាញ



**Erika C.B. Morales**

Partner, Morales + Morales Partners



**Ernesto Chaves**

LA Metro, Highway Programs



**Michael Cano**

LA Metro, Countywide Planning



**KeAndra Cylear Dodds**

LA Metro, Equity and Race

Metro

# គោលដៅកម្មវត្ថុ និងទម្រង់

**គោលដៅ**

អង្គប្រជុំការស្តាប់នានាត្រូវបានបង្កើតឡើងដើម្បីបង្ហាញព័ត៌មានអំពីការងាររបស់ក្រុមការងារផ្លូវ 710 (710 Task Force) ហើយសំខាន់បំផុត ដើម្បីទទួលបានការចូលរួមពីសមាជិកសហគមន៍អំពីរបៀបដែលការងាររបស់ក្រុមការងារផ្លូវ 710 អាចឆ្លុះបញ្ចាំងបានល្អបំផុតពីតម្រូវការ គោលដៅ និងអាទិភាពនានារបស់សហគមន៍។

## កម្មវត្ថុ

ក្នុងអំឡុងពេលកិច្ចប្រជុំទាំងពីរនេះ យើងនឹង៖

> ផ្តល់ព័ត៌មានថ្មីៗអំពីស្ថានភាពនៃរបាយការណ៍/សេចក្តីថ្លែងការណ៍ផលប៉ះពាល់បរិស្ថានផ្លូវ I-710 ភាគខាងត្បូង (EIR/EIS) ដែលត្រូវបានផ្អាក

> ពិនិត្យមើលគោលបំណង និងដំណើរការសម្រាប់ក្រុមការងារផ្លូវ 710 ថ្មី។

> ពិភាក្សាអំពីក្តីកង្វល់ គោលដៅ និងចក្ខុវិស័យរបស់សហគមន៍សម្រាប់តំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង ហើយស្តាប់ការណែនាំអំពីវិធីល្អបំផុតសម្រាប់ Metro និង Caltrans ដើម្បីរក្សាសហគមន៍ឱ្យចូលរួមក្នុងដំណើរការនេះ

Metro

# សូមអរគុណសម្រាប់ការចូលរួមជាមួយពួកយើង!

**របៀបវារៈ**

ម៉ោង 5:30 ល្ងាច ការស្វាគមន៍ សេចក្តីណែនាំ និងរបៀបវារៈ

ម៉ោង 5:35 ល្ងាច ស្ថានភាពនៃការផ្អាកតំបន់ខ្សែបន្ទាត់ផ្លូវ I-710

ម៉ោង 6:10 ល្ងាច កិច្ចពិភាក្សាសហគមន៍ស្តីពីអនាគតរបស់តំបន់ខ្សែបន្ទាត់ផ្លូវ I-710

ម៉ោង 6:55 ល្ងាច មតិយោបល់បញ្ចប់ & ការថ្លែងអំណរគុណ

Metro

# ប្រវត្តិគម្រោង

Metro

# ការផ្អាកគម្រោង I-710 ភាគខាងត្បូង

- ស្ថានភាព៖ ត្រូវបានផ្អាក (ខែឧសភា ឆ្នាំ2021)
- គោលបំណង៖ បង្កើតយុទ្ធសាស្ត្រដើម្បីដោះស្រាយការកកស្ទះ និងសុវត្ថិភាពសម្រាប់បញ្ហាអ្នកដំណើរ និងរថយន្តដឹកទំនិញពីកំពង់ផែ Long Beach និង Los Angeles ទៅផ្លូវ I-60។
- **ព្រឹត្តិការណ៍សំខាន់៖**
  - 2001 – ការផ្តួចផ្តើមនៃការសិក្សាតំបន់ខ្សែបន្ទាត់សំខាន់
  - 2012 – ចរាចរណ៍ដំបូងនៃរបាយការណ៍/សេចក្តីថ្លែងការណ៍ផលប៉ះពាល់បរិស្ថាន (EIR/EIS)
  - 2017 –ការធ្វើចរាចរឡើងវិញនៃ EIR/EIS
  - 2021 – គម្រោងដែលត្រូវបានផ្អាក
- ជំហានបន្ទាប់៖ CalTrans និង Metro បញ្ចប់ EIR/EIS




Metro

# ប្រវត្តិ និងសាវតាតំបន់ខ្សែបន្ទាត់ផ្លូវ I-710

- សហគមន៍តំបន់ខ្សែបន្ទាត់ផ្លូវ 710 បានរងផលប៉ះពាល់ពីសេចក្ដីសម្រេចចិត្តស្ដីពីការវិនិយោគលើការដឹកជញ្ជូនមិនស្មើភាពជាយូរមកហើយ មុនពេលដែលផ្លូវល្បឿនលឿន 710 ត្រូវបានសាងសង់ និងបើកឲ្យប្រើប្រាស់នៅឆ្នាំ 1964។
- គោលនយោបាយសាធារណៈកន្លងមកបានអនុញ្ញាតឱ្យមានការបែងចែកពូជសាសន៍តាមរយៈគោលនយោបាយកំណត់តំបន់ក្រហម ដែលបានប៉ះពាល់ដល់លំនាំនានានៃការអភិវឌ្ឍ ការវិនិយោគផ្នែកហិរញ្ញវត្ថុ ហេដ្ឋារចនាសម្ព័ន្ធ និងឪណាមិចសង្គមនៅក្នុងសហគមន៍នានានៃខោនធី LA ។
- ការផ្លាស់ទីទំនិញទៅ និងមកពីកំពង់ផែ LA និង Long Beach និងមជ្ឈមណ្ឌលភ័ស្តុភារ និងចែកចាយក្នុងតំបន់ដែលមានទីតាំងនៅតាមបណ្ដោយតំបន់ខ្សែបន្ទាត់ផ្លូវ 710 បានបង្កើតផលប៉ះពាល់អវិជ្ជមានដល់សុខភាពសាធារណៈ សេដ្ឋកិច្ច សុវត្ថិភាព និងគុណភាពនៃជីវិតសម្រាប់សហគមន៍តាមតំបន់ខ្សែបន្ទាត់។
- សរុបមក គោលនយោបាយទាំងនេះបានបង្កើតផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងយូរអង្វែងដល់សហគមន៍ដែលកាន់តែបង្កភាពធ្ងន់ធ្ងរឡើងដោយសារកំណើនប្រជាជនក្នុងតំបន់ និងការផ្លាស់ទីទំនិញតាមកំពង់ផែ។
- ដើម្បីវិនិយោគប្រកបដោយប្រសិទ្ធភាពនៅក្នុងតំបន់ខ្សែបន្ទាត់ផ្លូវ 710 យើងត្រូវយល់អំពីសេចក្ដីសម្រេចចិត្តដែលមិនស្មើភាពនាពេលកន្លងមក និងផលប៉ះពាល់រយៈពេលយូរអង្វែងជាជំនាន់នៃការសម្រេចចិត្តទាំងនេះ លើសហគមន៍ផ្លូវ 710 នាពេលបច្ចុប្បន្ននេះ។




Metro

# ក្រុមការងារផ្លូវ 710

# ក្រុមការងារផ្លូវ 710៖ ការប្រមើលមើលគម្រោងឡើងវិញ

> ដំណើរការ និងផែនការថ្មី៖ ក្រុមប្រឹក្សា Metro បានអំពាវនាវឱ្យមានដំណើរការថ្មីមួយសម្រាប់ពិនិត្យមើលពីរបៀបធ្វើឱ្យប្រសើរឡើងនៅក្នុងតំបន់ខ្សែបន្ទាត់ផ្លូវ 710 ដែលផ្តោតលើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធក្នុងតំបន់។ ជាការឆ្លើយតប Metro និង Caltrans បានផ្តួចផ្តើមក្រុមការងារផ្លូវ 710 ក្នុងខែកញ្ញា ឆ្នាំ2021 ។

> គោលដៅ៖ បង្កើតដំណើរការចូលរួមសហការដែលអ្នកពាក់ព័ន្ធក្នុងតំបន់ សហគមន៍ដែលរងផលប៉ះពាល់ និងដៃគូក្នុងតំបន់អាចធ្វើការរួមគ្នាបាន ដើម្បីបង្កើតវិធីសាស្រ្តថ្មីក្នុងការវិនិយោគនៅក្នុងតំបន់ខ្សែបន្ទាត់ផ្លូវ 710 ដែលនឹងកាត់បន្ថយភាពមិនស្មើគ្នា បង្កើនអត្ថប្រយោជន៍ និងកែលម្អការធ្វើបម្លាស់ទី និងសុវត្ថិភាពនៅក្នុងតំបន់ខ្សែបន្ទាត់នេះឲ្យកាន់តែមានភាពប្រសើរឡើង សម្រាប់អ្នករស់នៅក្នុងតំបន់ និងការផ្លាស់ទីរបស់ប្រជាជននិងទំនិញក្នុងតំបន់

> សមធម៌៖ Metro និង Caltrans នឹងធ្វើការជាមួយក្រុមការងារផ្លូវ 710 ដើម្បីផ្តោតលើសមធម៌ក្នុងការងាររបស់ពួកគេដោយស្វែងរកការចូលរួមជាមួយសហគមន៍ដែលរងផលប៉ះពាល់ ការយល់ដឹងពីភាពមិនស្មើគ្នាដែលបានជួបប្រទះ និងបង្កើតវិធីសាស្ត្រចម្រុះក្នុងការផ្តល់អត្ថប្រយោជន៍សម្រាប់ សហគមន៍ទាំងនេះ ខណៈធ្វើការកែលម្អការធ្វើបម្លាស់ទី សុវត្ថិភាព និងគុណភាពខ្យល់ក្នុងតំបន់ផងដែរ។

# សមាជិកភាពក្រុមការងារផ្លូវ 710

**710 Task Force**
Stakeholder Engagement and Participation

**Regional Agency**
- Metro
- SCAG
- CalTrans District 7
- LA County Public Works

**CBOs and Advocacy Groups**
- Members of CEHAJ
- SELA Collaborative
- California Endowment

**Freight Industry**
- Ports
- Railroads
- Trucking
- Logistics

**Labor and Economic / Workforce Development**
- Teamsters
- ILWU
- BizFed
- LAEDC

**Academic / Research / Policy**
- METRANS
- CSULB / CITT
- USC ERI
- CalStart

**Regional Transit**
- Long Beach Transit
- Metrolink

**Local Jurisdictions**
- County Supervisorial Districts (1, 2, 4)
- Long Beach
- Los Angeles

**Air Quality**
- CARB
- SCAQMD

Metro

# ដំណើរការរបស់ក្រុមការងារផ្លូវ 710 រហូតមកដល់បច្ចុប្បន្ន

- Metro និង Caltrans បានរៀបចំកិច្ចប្រជុំក្រុមការងារផ្លូវ 710 ចំនួនពីរ។
- Metro និង Caltrans បានកោះប្រជុំក្រុមការងារ (ការទំនាក់ទំនងសហគមន៍ កិច្ចព្រមព្រៀងជួល និងកិច្ចព្រមព្រៀងសហគមន៍ និងកម្មវិធីកាត់បន្ថយផ្សែងពុលយានយន្ត) ជាមួយសមាជិកក្រុមការងារផ្លូវ 710 ។
- ក្រុមការងារទំនាក់ទំនងសហគមន៍បានជួបប្រជុំ និងផ្តល់មតិចូលរួមក្នុងអង្គប្រជុំការស្តាប់នេះ និងការបង្កើតគណៈកម្មការប្រឹក្សាសហគមន៍នាពេលអនាគត។
- ក្រុមការងារកិច្ចព្រមព្រៀងជួល និងកិច្ចព្រមព្រៀងសហគមន៍បានពិភាក្សាអំពីដំណើរការធ្វើសេចក្តីសម្រេចចិត្ត រចនាសម្ព័ន្ធថ្នាក់ដឹកនាំនៃក្រុមការងារផ្លូវ 710 និងចំណុចផ្សេងទៀតនៃរបៀបដែលក្រុមការងារផ្លូវ 710 នឹងដំណើរការ។
- ក្រុមការងារកម្មវិធីកាត់បន្ថយផ្សែងពុលយានយន្តនៅផ្លូវ 710 ភាគខាងត្បូងត្រូវបានកោះប្រជុំសម្រាប់ការពិភាក្សាដំបូងស្តីពីការណែនាំរបស់ក្រុមប្រឹក្សា Metro ដើម្បីបង្កើតកម្មវិធីកាត់បន្ថយផ្សែងពុលយានយន្តថ្មី។




ស្វែងរកឯកសារគម្រោងបន្ថែមនៅ៖ https://www.metro.net/projects/i-710-corridor/#documents




ស្វែងរកឯកសារគម្រោងបន្ថែមនៅ៖ https://www.metro.net/projects/i-710-corridor/#documents

# សំណួរសម្រាប់សហគមន៍តំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង

> តើអ្នកមានក្តីកង្វល់អ្វីខ្លះអំពីគម្រោង I-710ភាគខាងត្បូងដើមដំបូង និងដំណើរការ?

> តើអ្នកមានសំណួរអ្វីអំពីព័ត៌មានដែលបានបង្ហាញដែរឬទេ?

# ការពិភាក្សាសហគមន៍

Metro

# ទម្រង់ការពិភាក្សា

- យើងបានរកឃើញសំណួរនាំមុខចំនួនបី
- សូមប្រើមុខងារលើកដៃនិម្មិត ដើម្បីតម្រង់ជួរ ឬដាក់សំណួរជាលាយលក្ខណ៍អក្សរតាមរយៈមុខងារ
- វាគ្មិននីមួយៗនឹងមានឱកាសផ្តល់មតិយោបល់ខ្លីៗ ហើយអ្នកសម្របសម្រួលនឹងដឹកនាំការសន្ទនាដើម្បីបង្កើនឲ្យវាគ្មិនបាននិយាយឲ្យបានច្រើនតាមពេលវេលា។
- ក្រុមការងារគម្រោងនឹងផ្តល់សេចក្តីសង្ខេបនៃមតិយោបល់ដល់ក្រុមការងារផ្លូវ 710 បន្ទាប់ពីអង្គប្រជុំបានបញ្ចប់
- ក្រុមការងារផ្លូវ 710 នឹងឆ្លុះបញ្ចាំងពីលទ្ធផលពីអង្គប្រជុំការស្តាប់ និងធ្វើរួមបញ្ចូលគ្នានូវតម្រូវការ គោលដៅ និងអាទិភាពនានារបស់សហគមន៍ ក្នុងដំណើរការបង្កើតអនុសាសន៍

Metro

# សំណួរសម្រាប់សមាជិកតំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង

- តើគោលដៅ/ចក្ខុវិស័យរបស់អ្នកចំពោះតំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូងមានអ្វីខ្លះ?
- តើតម្រូវការអ្វីខ្លះដែលត្រូវដោះស្រាយ?
- តើអ្វីជាវិធីល្អបំផុតក្នុងការចែករំលែកព័ត៌មាននិងចូលរួមជាមួយអ្នកនិងសហគមន៍របស់អ្នកតាមរយៈដំណើរការថ្មីរបស់ក្រុមការងារផ្លូវ 710?

# កាលបរិច្ឆេទនៃកិច្ចប្រជុំក្រុមការងារផ្លូវ 710 បន្ទាប់

> កិច្ចប្រជុំលើកទី #3៖ ថ្ងៃចន្ទ ទី13 ខែធ្នូ ឆ្នាំ2021 វេលាម៉ោង 5:00 ល្ងាច

- តំណភ្ជាប់សិក្ខាសាលាតាមអនឡាញ៖ https://bit.ly/3xksjyu
- អត្តលេខសិក្ខាសាលាតាមអនឡាញ៖ 881 5503 3286
- លេខសម្ងាត់៖ 5851
- ការហៅចូលជាភាសាអង់គ្លេស៖ (213) 338-8477

> កិច្ចប្រជុំលើកទី #4៖ ថ្ងៃចន្ទ ទី10ខែមករា ឆ្នាំ2022 វេលាម៉ោង 5:00 ល្ងាច

> កិច្ចប្រជុំលើកទី #5៖ ថ្ងៃព្រហស្បតិ៍ ទី17 ខែកុម្ភៈ ឆ្នាំ2022 វេលាម៉ោង 5:00 ល្ងាច

កាលបរិច្ឆេទកិច្ចប្រជុំបន្ថែមនឹងត្រូវបានប្រកាសនៅកិច្ចប្រជុំថ្ងៃទី10 ខែមករា ឆ្នាំ2021។

Metro

# រក្សាទំនាក់ទំនងជាមួយគម្រោងនេះ

Michael Cano, *Deputy Executive Officer, Countywide Planning & Development*
Metro
One Gateway Plaza, MS 99-13-1
Los Angeles, CA 90012

213.922.4710

*710corridor@metro.net*

*metro.net/projects/i-710-corridor*

*@metrolosangeles*

*losangelesmetro*

Metro

សូមអរគុណដែលបានចូលរួមជាមួយយើង ខ្ញុំ !

Metro